ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១១/៩៤១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៨/១២៣៥ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០១១/៩៤១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងមាត្រា៦នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

www.pheakdeylaw.com

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះ កំណត់អំពីបេសកកម្ម សិទ្ធិអំណាច មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

ជំពូកទី២

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

មាត្រា២.-

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានតួនាទីជាអង្គភាពប្រតិបត្តិ និងជាសេនាធិការផ្ទាល់នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរង ព្រមទាំងសមាជិកមួយចំនួនជាជំនួយការ។

មាត្រា៣.-

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានបេសកកម្មជួយអាជ្ញាធរក្នុងការដោះស្រាយនិងសម្របសម្រួលចំពោះរាល់ទំនាស់ដីធ្លី និងមានភារកិច្ចដូចមានកំណត់ក្នុងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ស្របតាមការសម្រេចរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិចេញលិខិតណែនាំឱ្យរក្សាស្ថានភាពដើម ឬផ្អាកសកម្មភាពផ្សេងៗជាបណ្តោះអាសន្ននៅទីតាំងទំនាស់ ក្រោយពីទទួលពាក្យបណ្តឹង ឬពាក្យសុំអន្តរាគមន៍ពីគូវិវាទ ឬតាមតម្រូវការនៃសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

មាត្រា៤.-

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយខែម្តង តាមការអញ្ជើញនិងការណែនាំរបស់អគ្គលេខាធិការ ហើយអាចធ្វើការប្រជុំបន្ទាន់ក្នុងករណីចាំបាច់។

www.pheakdeylaw.com

មាត្រា៥.-

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងពេលបំពេញភារកិច្ច និងបេសកកម្មរបស់ខ្លួន។

ជំពូកទី៣

មន្ត្រី បុគ្គលិក

មាត្រា៦.-

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រើប្រាស់បុគ្គលិកនៃមុខងារសាធារណៈ។ លក្ខខណ្ឌនៃប្រាក់បំណាច់ពិសេសសម្រាប់បើកជូនបុគ្គលិកនៃមុខងារសាធារណៈ ដែលបំពេញភារកិច្ចជូនអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់អគ្គលេខាធិការ។

មាត្រា៧.-

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដោយមានការឯកភាពពីប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អាចប្រើប្រាស់អង្គភាពនិងមន្ត្រីជំនាញនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការបំពេញបេសកកម្ម តួនាទី និងភារកិច្ចរបស់ខ្លួន។

ជំពូកទី៤

អវសានប្បញ្ញត្តិ

មាត្រា៨.-

អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៩.-

មន្ត្រីនិងបុគ្គលិកទាំងអស់ដែលកំពុងបម្រើការនៅក្នុងនាយកដ្ឋាននានា នៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវវិលត្រឡប់ទៅបម្រើការងារនៅអង្គភាពដើមវិញ។

www.pheakdeylaw.com

មាត្រា១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៤កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

ជា សុផារ៉ា

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com